មជ្ឈមណ្ឌលឯកសារកម្ពុជា

# កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្លេងយុត្តិធម៌៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## វគ្គទី៣

## ប្រធានបទ៖ តើការអត់ឃ្លានវិវត្តន៍ទៅយ៉ាងដូចម្តេច ហើយមេដឹកនាំខ្មែរក្រហមបានដឹងអ្វីខ្លះទាក់ទងនឹងការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម?

*ដោយ ៖ វ៉ែនឌូល ឌីហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ ៖ ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែឧសភា ឆ្នាំ២០១៣*

*ជម្រាបសួរប្រិយមិត្តអ្នកស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៣ ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់យើងខ្ញុំ ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រ និងច្បាប់ផ្សេងៗដែលទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម ។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្តាប់ ។ ចំពោះប្រិយមិត្តអ្នកស្តាប់ដែលរស់នៅរាជធានីភ្នំពេញ និងខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ*

*តាមរយៈ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។*

*ការផ្សាយក្នុងវគ្គនេះ យើងខ្ញុំផ្តោតសំខាន់ទៅលើការវិវត្តន៍នៃការអត់ឃ្លាន និងធ្វើការប្រៀបធៀបទៅនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហម និងស្វែងយល់ថា តើមេដឹកនាំខ្មែរក្រហមសំខាន់ៗ បានដឹងអ្វីខ្លះទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅរបបខ្មែរក្រហម? សំនួរទាំងអស់ខាងលើនេះមានសារៈសំខាន់ក្នុងការកំណត់ថា តើគោលនយោបាយដែលបានបង្កើតឡើងដោយមេដឹកនាំខ្មែរក្រហមអាចជាឧក្រិដ្ឋកម្ម ឬគ្រាន់តែជាកំហុសឆ្គងនៃការដឹកនាំ?*

*មុននឹងយើងចាប់ផ្តើមបទអត្ថាធិប្បាយវគ្គបីនេះ យើងខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកស្តាប់ អំពីការវិវឌ្ឍរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅសល់តែពីរនាក់ប៉ុណ្ណោះគឺ នួន ជា និង ខៀវ សំផន បន្ទាប់ពី អៀង សារី បានស្លាប់ដោយសារជំងឺកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និង អៀង ធីរិទ្ធ ដែលជាប្រពន្ធរបស់ អៀង សារី ត្រូវបានតុលាការដោះលែងឲ្យនៅក្រៅឃុំ ដោយសារតុលាការរកឃើញថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ ។ អៀង សារី បានស្លាប់មុនការប្រកាសសាលក្រមរបស់តុលាការ នេះមានន័យថា រាល់បទចោទប្រកាន់ទាំងឡាយដែលពាក់ព័ន្ធនឹង អៀង សារី នឹង ត្រូវលុបចេញពីសំណុំរឿង ។ ម្យ៉ាងវិញទៀត នៅពេលដែលបទចោទប្រកាន់នឹង អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានដកចេញពីសំណុំរឿង តុលាការនឹងមិនអាចធ្វើការដកហូតទ្រព្យសម្បត្តិរបស់ជនជាប់ចោទទាំងពីរ សម្រាប់ប្រើប្រាស់នៅក្នុងគម្រោងសំណងជំងឺចិត្តដល់ជនរងគ្រោះបាននោះទេ ។*

## ***សេចក្តីផ្តើម***

*ដូចដែលយើងបានពិភាក្សានៅក្នុងវគ្គទី២កន្លងមក កង្វះអាហារូបត្ថម្ភបានបង្កជាបញ្ហាសុខភាពដែលធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយ និងស្មារតីរបស់មនុស្ស ព្រមទាំងធ្វើឲ្យបុគ្គលនោះងាយស្រួលឆ្លងនូវជំងឺផ្សេងៗ ។*

នៅពេលដែលការអត់ឃ្លានកើតមានឡើងចំពោះប្រជាជន នោះវានឹងធ្វើឲ្យមានការប៉ះពាល់ដល់សង្គមទាំងមូល ។ នៅពេលដែលមនុស្សគ្រប់គ្នាខំត្រដររស់ក្នុងកាលៈទេសៈដែលសង្គមទាំងមូលកំពុងជួបប្រទះការអត់ឃ្លាន មនុស្សអាចចាប់ផ្តើមបែកបាក់សាមគ្គី បាត់បង់សីលធម៌សង្គម ហើយអំពើហិង្សាអាចនឹងកើតមាន ។ ជាឧទាហរណ៍ នៅពេលដែលការអត់ឃ្លានកើតឡើង ឪពុកម្តាយអាចនឹងលក់ខ្លួនឯង ឬកូនៗរបស់ខ្លួនឲ្យធ្វើជាទាសករ ដោយសង្ឃឹមនឹងទទួលបានអាហារបរិភោគច្រើនជាងមុន ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាជាច្រើនបាននាំគ្នាចុះចូលជាមួយខ្មែរក្រហម ដោយសង្ឃឹមថានឹងអាចទទួលបានរបបអាហារល្អប្រសើរជាងមុន បើទោះជាដឹងថារបបខ្មែរក្រហមបានធ្វើឲ្យប្រជាជនទាំងនោះក្លាយទៅជាមនុស្សឃោរឃៅក៏ដោយ ។ ជាងនេះទៅទៀត នៅពេលដែលរបបខ្មែរក្រហមជិតដួលរលំ បក្សកុម្មុយនីសកម្ពុជាបានប្រកាសថា ប្រជាជនគ្រប់វណ្ណៈទាំងអស់អាចចុះឈ្មោះចូលបម្រើកងទ័ពបដិវត្តន៍បាន បើទោះបីជាប្រជាជនមួយចំនួនមិនមានប្រវត្តិបដិវត្តន៍ស្អាតស្អំពីមុនក៏ដោយ ។ នៅពេលនោះ មានប្រជាជនជាច្រើនបានស្ម័គ្រចូលបម្រើកងទ័ពខ្មែរក្រហមក្នុងការច្បាំង ប្រឆាំងនឹងកងទ័ពវៀតណាមនៅសមរភូមិមុខ ដោយសង្ឃឹមថានឹងទទួលបានអាហារូបត្ថម្ភប្រសើរជាងមុន ។

នៅពេលដែលមានការអត់ឃ្លានកើតឡើង អត្រានៃការធ្វើអត្តឃាតក៏កើតមានឡើងដែរ ហើយនេះក៏ជាករណីមួយដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជានារបបខ្មែរក្រហម ។ ធ្ងន់ធ្ងរជាងនេះទៅទៀត នៅពេលដែលការអត់ឃ្លានអូសបន្លាយរយៈពេលយូរ និងឈានដល់ដំណាក់កាល ធ្ងន់ធ្ងរខ្លាំង អំពើសាហាវព្រៃផ្សៃផ្សេងៗអាចនឹងកើតមាន ដូចជាការបរិភោគសាច់មនុស្ស និងការសម្លាប់កូនខ្លួនឯងជាដើម ។ ជាមួយគ្នានេះដែរ អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើន បាននិយាយថាសកម្មភាពដែលនឹកស្មានមិនដល់ទាំងនោះបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម ។

ជាទូទៅ នៅពេលដែលមានគ្រោះអត់ឃ្លានកើតឡើង ប្រជាជនតែងតែខិតខំស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីកាត់បន្ថយការឈឺចាប់ដែលបង្កឲ្យដោយការអត់ឃ្លាន ។ មនុស្សមួយចំនួនបានខំដើររកប្រភពអាហារផ្សេងៗដែលមិនធ្លាប់បរិភោគពីមុនមក ។ ជាងនេះទៅទៀត ចលនាបំលាស់ទីទៅកាន់ទីកន្លែងដែលសម្បូរទៅដោយប្រភពចំណីអាហារចាប់ផ្តើមកើតឡើង ។ ដោយឡែក នៅក្នុងរបបខ្មែរក្រហម ប្រជាជនមិនអាចធ្វើសកម្មភាពស្វែងរកអាហារបែបនេះបានទេ ។ គោលនយោបាយរបស់ខ្មែរក្រហមបានហាមប្រាមរាល់ការបរិភោគជាលក្ខណៈឯកជន ហើយខ្មែរក្រហមបានប្រកាសថាអ្វីៗទាំងអស់ដែលមាននៅក្នុងប្រទេសកម្ពុជា គឺជាទ្រព្យសម្បត្តិរបស់អង្គការបដិវត្តន៍តែមួយគត់ ។ ដូច្នេះហើយ របស់របរទាំងនោះមិនអាចយកបានដោយគ្មានការអនុញ្ញាតពីខ្មែរក្រហមនោះទេ ។ ប្រជាជនទាំងអស់ត្រូវបានហាមប្រាមមិនឲ្យដើរស្វែងរកអាហារដោយសេរីនោះទេ ។ អាស្រ័យហេតុដូចនេះហើយ

ជនរងគ្រោះនៅក្នុងរបបខ្មែររបបត្រូវប្រឈមនឹងការធ្វើការសម្រេចចិត្តថា តើពួកគេត្រូវតែលួចរកអាហារបន្ថែមដោយលួចលាក់ ឬក៏ត្រូវពឹងផ្អែកទាំងស្រុងទៅលើតែរបបអាហារដែលផ្តល់ឲ្យដោយខ្មែរក្រហមនៅពេលបាយសហករណ៍? ប្រជាជនដែលសម្រេចចិត្តលួចអាហារបន្ថែមប្រឈមមុខនឹងការវាយធ្វើបាប ឬសម្លាប់ប្រសិនបើត្រូវបានខ្មែរក្រហមចាប់បាន។ ឯកសារដែលនៅសេសសល់ពីរបបខ្មែរក្រហមជាច្រើនបានរៀបរាប់ពីការចាប់ខ្លួនប្រជាជន ដែលបានលួចអាហាររបស់បដិវត្តន៍ ឬត្អូញត្អែរពីរបបអាហារដែលមិនគ្រប់គ្រាន់។ ក្រោយមកទៀត ជនរងគ្រោះទាំងអស់នោះត្រូវបានសម្លាប់។

ហេតុដូចច្នេះហើយ យើងសង្កេតឃើញថា ជនរងគ្រោះដោយការអត់ឃ្លានក្នុងរបបខ្មែរក្រហមមិនអាចស្វែងរកមធ្យោបាយណាមួយ ដើម្បីខបត្តម្ភខ្លួនឯងឲ្យរួចផុតពីការលំបាកដែលបង្កឡើងដោយការអត់ឃ្លានបាននោះទេ។ រាល់សកម្មភាពទាំងឡាយដែលប្រជាជនបានធ្វើ ដូចជាការស្វែងរកអាហារនៅក្នុងព្រៃ ឬការផ្លាស់ទីទៅកាន់តំបន់ដែលមានអាហារ ត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់ ហើយខ្មែរក្រហមបានដាក់ទោសដល់ប្រជាជនទាំងនោះ ដោយការសម្លាប់។ ពោលគឺ គ្មាននរណាម្នាក់អាចរត់រួចទេ។

## តើមេដឹកនាំខ្មែរក្រហមបានដឹងរឿងអ្វីខ្លះទាក់ទងទៅនឹងការអត់ឃ្លាន?

សំនួរដែលចោទសួរថា «តើមេដឹកនាំកំពូលៗរបស់ខ្មែរក្រហមបានដឹងអ្វីខ្លះទាក់ទងនឹងការអត់ឃ្លានដែលបានសម្លាប់ប្រជាជនកម្ពុជាអស់ជាច្រើននាក់?» គឺជាសំណួរមួយដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនចង់ដឹង។ ដាក់ស្តែង នួន ជា ដែលជាអតីតមេដឹកនាំខ្មែរក្រហមមួយរូបបាននិយាយជាសាធារណៈថា ខ្មែរក្រហមពិតជាបានប្រព្រឹត្តកំហុសឆ្គងមួយចំនួនមែន។ ប៉ុន្តែ នួន ជា បានអះអាងបន្តថា រដ្ឋាភិបាលខ្មែរក្រហមមិនទទួលខុសត្រូវចំពោះការបង្កឲ្យមានការអត់ឃ្លាននោះទេ។ ជាងនេះទៅទៀត នួន ជា បានបន្ថែមថា មេដឹកនាំខ្មែរក្រហមមជ្ឈិមបក្សនៅទីក្រុងភ្នំពេញ មិនបានដឹងពីលក្ខខណ្ឌរស់នៅពិតប្រាកដរបស់ប្រជាជននៅតាមជនបទនោះទេ ពីព្រោះកម្មាភិបាលថ្នាក់ក្រោមដែលគ្រប់គ្រងនៅតាមតំបន់ទាំងនោះបានធ្វើការរបាយការណ៍មិនពិតពីបរិមាណស្រូវដែលផលិតបាន និងបរិមាណអាហារដែលផ្តល់ទៅឲ្យប្រជាជន។

បើទោះបីជាមិនមានភស្តុតាង ឬព័ត៌មានជាក់លាក់ណាមួយបង្ហាញថា មេដឹកនាំខ្មែរក្រហមបានដឹងពីការអត់ឃ្លានដែលកើតមាននៅទូទាំងប្រទេសកម្ពុជា និងចំនួនប្រជាជនកម្ពុជាដែលត្រូវស្លាប់ដោយសារការអត់អាហារនិងជំងឺក៏ដោយ ក៏មានឯកសារជាច្រើនបានបង្ហាញថា មេដឹកនាំខ្មែរក្រហមបានដឹងអំពីស្ថានភាពទូទៅនៅតាមមូលដ្ឋានដូចខាងក្រោមៈ

*ទីមួយៈ* អំណាចទាំងស្រុងគឺស្ថិតនៅលើមេដឹកនាំមជ្ឈិមបក្ស ។ បន្ទាប់ពីកាន់កាប់អំណាច មេដឹកនាំខ្មែរក្រហមបានបង្កើតប្រព័ន្ធរាយការណ៍ថ្នាក់ជាតិមួយ ដែលតម្រូវឲ្យអ្នកដឹកនាំតាមតំបន់ទាំងអស់ផ្ញើទូរលេខអំពីការងារផ្សេងៗនៅទូទាំងប្រទេស ដូចជា ទិន្នផលស្រូវ ស្ថានភាពសន្តិសុខនៅតាមតំបន់ ទៅមន្ទីរមជ្ឈិមលេខ "៨៧០" នៅទីក្រុងភ្នំពេញ ។ តាមរយៈការរាយការណ៍ទាំងអស់នេះ អាចបង្ហាញឲ្យឃើញថា មេដឹកនាំខ្មែរក្រហមពិតជាបានដឹងពីអ្វីដែលបានកើតឡើងនៅតាមមូលដ្ឋាន ។

*ទីពីរៈ* មេដឹកនាំខ្មែរក្រហមបានត្រួតពិនិត្យនូវរាល់ព័ត៌មានក្រៅប្រទេសផ្សេងៗដែលចុះផ្សាយពីរបបខ្មែរក្រហម និងប្រធានបទដែលពាក់ព័ន្ធផ្សេងៗ ។ ជាក់ស្តែង អត្ថបទដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានទាំងនោះបានរៀបរាប់ថា ជនភៀសខ្លួនជាច្រើនដែលរត់គេចទៅប្រទេសថៃជួបប្រទះបញ្ហាកង្វះម្ហូបអាហារដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ជាការឆ្លើយតបទៅនឹងអត្ថបទសារព័ត៌មានទាំងនោះ មេដឹកនាំខ្មែរក្រហមបាននិយាយជំទាស់ថា របាយការណ៍ទាំងនោះបានបំភ្លៃការពិតពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។ ជាក់ស្តែង បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ អៀងធីរិទ្ធ ដែលជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចរបស់ខ្មែរក្រហម បានអះអាងនៅក្នុងបទសម្ភាសន៍ជាវីដេអូមួយថា "ខ្មែរក្រហមបានផ្តល់អាហារ សំលៀកបំពាក់ និងសេវាសុខភាពគ្រប់គ្រាន់ទៅឲ្យប្រជាជនកម្ពុជាគ្រប់ៗគ្នា" ។ ស្រដៀងគ្នានឹងនេះដែរ អៀង សារី ដែលជាអតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហម បានធ្វើការអះអាងនៅក្នុងវីដេអូមួយផ្សេងទៀតថា "មេដឹកនាំខ្មែរក្រហមមិនបានដឹងពីស្ថានភាពរស់នៅរបស់ប្រជាជនសាមញ្ញនៅតាមទីជនបទនោះទេ ។ នេះជាមូលហេតុមួយដែលបណ្តាលឲ្យមានអំពើឃាតកម្មកើតឡើង ។ ក៏ប៉ុន្តែ ឃាតករទាំងនោះ គឺជាភ្នាក់ងារវៀតណាម ។" ជាងនេះទៅទៀត នៅឆ្នាំ១៩៧៨ ជាឆ្នាំដែលប្រជាជនកម្ពុជារាប់ពាន់នាក់កំពុងតែស្លាប់ជាបន្តបន្ទាប់ដោយសារការអត់ឃ្លាន ប៉ុល ពត បែរជានិយាយនៅទៅកាន់អ្នកយកព័ត៌មានរបស់ប្រទេសចិនម្នាក់ថា ប្រទេសកម្ពុជាសម្បូរទៅដោយផលិតផលស្បៀងអាហារ ។ មិនតែប៉ុណ្ណោះ ប៉ុល ពត បានអះអាងថា "ប្រសិនបើយើងធ្វើការប្រៀបធៀបសេដ្ឋកិច្ច និងផលិតផលស្បៀងអាហាររវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម នោះយើងនឹងឃើញថា ប្រទេសកម្ពុជាមានស្បៀងអាហារគ្រប់គ្រាន់ ចំណែកឯ ប្រទេសវៀតណាមវិញ កំពុងតែញាំញីដោយបញ្ហាកង្វះខាតស្បៀងអាហារ ។ ដូច្នេះ យើងសង្កេតឃើញថាប្រទេសកម្ពុជាមានប្រៀបជាងប្រទេសវៀតណាមខាងស្បៀងអាហារ ។" វាគឺជារឿងមួយពិបាកនឹងជឿ នៅពេលដែលមេដឹកនាំខ្មែរក្រហមនិយាយថាខ្លួនមិនបានដឹងអំពីការអត់ឃ្លានដែលបានកើតឡើង ។ ផ្ទុយទៅវិញ មេដឹកនាំខ្មែរក្រហមបែរជាធ្វើការប្រកាសជាអន្តរជាតិថា ការអត់ឃ្លានមិនបានកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ ។

ទីបីៈ នៅក្នុងរបបខ្មែរក្រហម មេដឹកនាំខ្មែរក្រហមបានធ្វើទស្សនកិច្ចទៅកាន់តំបន់មូលដ្ឋានដើម្បីត្រួតពិនិត្យការងារ ។ មិនតែប៉ុណ្ណោះ មេដឹកនាំខ្មែរក្រហមបានធ្វើការបោសសំអាតកម្មាភិបាលខ្មែរក្រហមរូបណាដែលបានទទួលស្គាល់ថា ការអត់ឃ្លានពិតជាបានកើតមាននៅតំបន់ដែលខ្លួនគ្រប់គ្រង ។ បន្ថែមពីនេះទៅទៀត មេដឹកនាំខ្មែរក្រហមបានប្រគល់ទង់កិត្តិយសទៅឲ្យតំបន់ណាដែលអាចសម្រេចតាមផែនការរបស់បដិវត្តន៍ ។ ជាឧទាហរណ៍ ខ្មែរក្រហមបានប្រគល់ទង់កិត្តិយសទៅឲ្យតំបន់មួយចំនួននៃភូមិភាគនិរតី ដែលការអត់ឃ្លាននៅតំបន់ទាំងនោះមានលក្ខណៈមិនសូវធ្ងន់ធ្ងរដូចតំបន់ដទៀត ។ ពោលគឺផលិតផលស្រូវនៅភូមិភាគនិរតីច្រើនជាងតំបន់ផ្សេងៗទៀតនៃភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ ។ កត្តាផ្សេងទៀតដែលកម្មាភិបាលខ្មែរក្រហមនៅភូមិភាគនីរតីមិនត្រូវបានអង្គការចាប់ខ្លួន ពីព្រោះភូមិភាគនិរតីសម្រេចបានទិន្នផលស្រូវតាមផែនការកំណត់ និងមិនបានរាយការណ៍អំពីបញ្ហាណាមួយដែលទាក់ទងនឹងផលិតកម្មស្រូវ ។ មិនតែប៉ុណ្ណោះ តាម៉ុកគឺជាមេដឹកនាំភូមិភាគនីរតីដែលទទួលបានការជឿជាក់ពីសំណាក់ខ្មែរក្រហម នៅពេលដែលមេដឹកនាំដទៃទៀតនៃភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ាមិនត្រូវបាន ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមផ្សេងទៀតទុកចិត្តទាំងស្រុងនៅឡើយ ។ ម្ល៉ោះហើយ ខ្មែរក្រហមបានដាក់កំហិតឲ្យតំបន់ទាំងនោះផលិតផលស្រូវឲ្យបានច្រើនជាពិសេសតំបន់នៅភូមិភាគពាយ័ព្យ ។ នៅពេលដែលតំបន់ទាំងនោះមិនអាចសម្រេចទិន្នផលស្រូវតាមផែនការកំណត់ ឬបានរាយការណ៍ថាមានមនុស្សស្លាប់ដោយសារការអត់ឃ្លាន និងជំងឺ ខ្មែរក្រហមបានធ្វើការបោសំអាត និងសម្លាប់ថ្នាក់ដឹកនាំតាមមូលដ្ឋាន ។ ផ្ទុយទៅវិញ ខ្មែរក្រហមមិនបានចាត់វិធានការណាមួយ ដើម្បីដោះស្រាយបញ្ហាដែលបានកើតឡើងពាក់ព័ន្ធនឹងការអត់ឃ្លាននោះទេ ។ ជាក់ស្តែង នៅឆ្នាំ១៩៧៦ អៀង ធីរិទ្ធ បានធ្វើទស្សនកិច្ចដោយផ្ទាល់ទៅកាន់ភូមិភាគពាយ័ព្យ ហើយបានរាយការណ៍ទៅ ថ្នាក់ដឹកនាំបក្សថាប្រជាជននៅតាមមូលដ្ឋានកំពុងរស់នៅក្នុងលក្ខខណ្ឌដ៏អាក្រក់ ។ ប្រជាជននៅតំបន់ទាំងនោះទទួលរងគ្រោះដោយការអត់ឃ្លាន និងជំងឺរាក ។ បន្ទាប់ពីរបាយការណ៍ស្តីអំពីស្ថានភាពនៅភូមិភាគពាយ័ព្យត្រូវបានបញ្ជូនទៅថ្នាក់ដឹកនាំបក្ស ខ្មែរក្រហមបានបញ្ជូនកម្មាភិបាលខ្មែរក្រហមពីភូមិភាគនីរតីទៅកាន់ភូមិភាគពាយ័ព្យ និងធ្វើការបោសសំអាតថ្នាក់ដឹកនាំភូមិភាគពាយ័ព្យទាំងស្រុង ។ ដូច្នេះ យើងសង្កេតឃើញថាជំនួសឲ្យការស្វែងរកដំណោះស្រាយទៅលើបញ្ហាអត់ឃ្លានដែលកំពុងតែកើតមាន ថ្នាក់ដឹកនាំបក្សបែរជាស្តីបន្ទោសកម្មាភិបាលដឹកនាំថ្នាក់ក្រោម និងបានសម្លាប់កម្មាភិបាលថ្នាក់ក្រោមទៅវិញ ។

ដោយផ្អែកលើឧទាហរណ៍ដែលបានលើកឡើងខាងលើ យើងអាចសន្និដ្ឋានបានថា មេដឹកនាំខ្មែរក្រហមបានដឹងយ៉ាងច្បាស់ថាមានប្រជាជនជាច្រើននៅតាមមូលដ្ឋានកំពុងតែជួបប្រទះការអត់ឃ្លាននៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហម ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំខ្មែរក្រហមបាន

ជ្រើសរើសការប្រើប្រាស់អំពើហិង្សា និងការស្តីបន្ទោសទៅលើកម្មាភិបាលថ្នាក់ក្រោមអំពីបញ្ហាដែលបានកើតឡើង ដោយមិនបានពិចារណាក្នុងការផ្លាស់ប្តូរនូវគោលនយោបាយរបស់ខ្លួនដែលបណ្តាលឲ្យមានការអត់ឃ្លានកើតឡើង ។ ការប្រើប្រាស់អំពើហិង្សា និងការសង្ស័យចំពោះកម្មាភិបាលថ្នាក់ក្រោមបានធ្វើឲ្យប្រជាជនទូទៅជួបប្រទះការអត់ឃ្លាន និងបានបង្កជាផលវិបាកផ្សេងៗដល់កម្មាភិបាលថ្នាក់ក្រោមនៅតាមមូលដ្ឋាន ។ ពោលគឺ ចំពោះកម្មាភិបាលថ្នាក់មូលដ្ឋានរូបណាដែលទទួលស្គាល់ថា តំបន់របស់ខ្លួនគ្រប់គ្រងមិនអាចសម្រេចបានទិន្នផលស្រូវតាមផែនការកំណត់របស់បក្ស កម្មាភិបាលរូបនោះត្រូវប្រឈមនឹងការបោសសំអាតយ៉ាងព្រៃផ្សៃបំផុត ។ ផ្ទុយទៅវិញ ប្រសិនបើកម្មាភិបាលថ្នាក់មូលដ្ឋានរូបណាដែលអាចផ្តល់ទិន្នផលស្រូវតាមតម្រូវការរបស់មជ្ឈិមបក្ស កម្មាភិបាលរូបនោះអាចគេចផុតពីការបោសសំអាតរបស់បក្ស ។ ដូច្នេះ ប្រជាជនទូទៅណាដែលប៉ុនប៉ងរកអាហារបន្ថែម ត្រូវប្រឈមមុខនឹងការប្រើអំពើហិង្សា និងការសម្លាប់ ។

ពាក្យស្លោកខ្មែរក្រហមបានលើកឡើងថា អង្គការខ្មែរក្រហមជា "អង្គការភ្នែកម្នាស់" និងអាចដឹងគ្រប់រឿងរ៉ាវទាំងអស់ដែលបានកើតឡើង ។ ពាក្យស្លោកដ៏គួរឲ្យខ្លាចមួយឃ្លានេះ ពិតជាស្តែងឡើងចំពោះបុគ្គលណាដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់អង្គការ ។ យោងតាមពាក្យស្លោកមួយឃ្លានេះ អង្គការបានត្រឹមតែអង្គុយមើលប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនទទួលរងទុក្ខវេទនា និងស្លាប់ដោយសារការអត់ឃ្លាន ប៉ុន្តែ មិនបានធ្វើអ្វីដើម្បីជួយដោះស្រាយបញ្ហានៃទុក្ខវេទនារបស់ប្រជាជននោះទេ ។

ប្រិយមិត្តអ្នកស្តាប់ជាទីមេត្រី សម្រាប់ការផ្សាយនៅវគ្គក្រោយនេះ យើងនឹងផ្តោតសំខាន់ទៅលើបទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍ និងធ្វើការពិនិត្យថា តើការបង្កឲ្យមានការអត់ឃ្លានអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍ដែរឬទេ?

*(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកអត្ថបទមួយក្រោមចំណងជើងថា "អំពើល្អរបស់ សោ វ៉ាន់" ចេញផ្សាយដោយទស្សនាវដ្តី"ស្វែងរកការពិត"របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១០៨ ខែធ្នូ ឆ្នាំ២០០៨ សរសេរដោយ សុខ វណ្ណៈ ។)*

# អំពើល្អរបស់ សៅ ភ៉ាន់

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅកាន់ទីជនបទ ដោយបង្អត់អាហារ បង្ខំឲ្យធ្វើការហួសកម្លាំង និងយកមនុស្សទៅសម្លាប់ដោយគ្មានជំនុំជម្រះទោសតាមផ្លូវច្បាប់ឡើយ ។ អ្នកដែលធំដឹងក្តីនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនិងក្រោយរបបនេះសុទ្ធតែទទួលស្គាល់ថា របបខ្មែរក្រហមជារបបសាហាវឃោរឃៅព្រោះបានសម្លាប់មនុស្សអស់ជិតពីរលាននាក់ ។ ទោះយ៉ាងណាក៏ដោយក៏នៅមានកម្មាភិបាលខ្មែរក្រហមមួយចំនួនតូចព្យាយាមធ្វើអំពើល្អដែរ ដោយចេះជួយអាសាអ្នកដទៃនៅពេលដែលអ្នកណាម្នាក់ប្រព្រឹត្តខុសអង្គការវិន័យ ។

ភ៉ាន់ មានស្រុកកំណើតនៅភូមិស្រែខ្វាវ ឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ មានឪពុកឈ្មោះ សៅ មី ម្តាយឈ្មោះ សុខពេន ។ ភ៉ាន់ ជាកូនទី៧ ក្នុងចំណោមបងប្អូន៨នាក់ (ប្រុស៣និងស្រី៥) ។ ដោយសាររដ្ឋប្រហារនៅឆ្នាំ១៩៧០ ភ៉ាន់ បានសម្រេចចិត្តឈប់រៀន ត្រឹមថ្នាក់ទី១១ (សង្គមចាស់) មកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ នៅឆ្នាំ១៩៧១ ភ៉ាន់ បានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខាងផ្នែកសិល្បៈ ។ ដោយសារតែកម្មាភិបាលថ្នាក់ស្រុកពេញចិត្តការងាររបស់គាត់ដែលធ្វើបានល្អ ភ៉ាន់ ក៏ត្រូវបានតែងតាំងឲ្យទៅធ្វើជានិរសារប្រចាំមន្ទីរ២៥០ តំបន់១៣ ។ នៅឆ្នាំ១៩៧៣ អង្គការផ្លាស់ ភ៉ាន់ ឲ្យធ្វើជាប្រធាននារីឃុំពេលដើម្បីពង្រឹងប្រជាជននៅតាមមូលដ្ឋានវិញ ។


សៅ ភ៉ាន់

នៅឆ្នាំ១៩៧៥ រយៈពេលមួយខែក្រោយពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះ អង្គការបានផ្លាស់ ភ៉ាន់ ឲ្យទៅធ្វើស្រែអំបិលនៅភូមិកំពង់កណ្តាល ខេត្តកំពតវិញ ដោយមានតួនាទីជាប្រធានអនុសេនាធំគ្រប់គ្រងកម្មករចំនួន៧០នាក់ ក្រោយមក១០០នាក់ ។ នៅទីនេះ ភូមិសាស្ត្រមានលក្ខណៈអំណោយផលណាស់ព្រោះមានផ្ទៃដីធំទូលាយ និងមានផ្ទះចំនួន៥ខ្នងសម្រាប់ឲ្យកម្មករស្នាក់នៅ ។ លើសពីនេះ ភ៉ាន់ មិនដែលព្រួយបារម្ភថាខ្វះបាយនិងម្ហូបសម្រាប់ហូបទេ ។ ប៉ុន្តែ ភ៉ាន់ បែរជាមិនដែលទទួលបានការអនុញ្ញាតឲ្យត្រឡប់មកលេងស្រុកកំណើតទាល់តែសោះ ។ ព្រោះតែបាត់ដំណឹង ភ៉ាន់ យូរពេក នៅឆ្នាំ១៩៧៧ ម្តាយរបស់គាត់ក៏មកលេងគាត់ដល់កន្លែងធ្វើការតែម្តង ហើយថែមទាំងបានរៀបរាប់រឿងរ៉ាវទាំងអស់ដែលកើតឡើងនៅក្នុងភូមិថានៅតាមជនបទខ្មែរក្រហមបានសម្លាប់ប្រជាជនជាច្រើន ហើយផ្តល់អាហារឲ្យប្រជាជនហូបមិនគ្រប់គ្រាន់ទេ ។ ប៉ុន្តែ ភ៉ាន់ មិនជឿពីព្រោះគាត់ឃើញកន្លែងគាត់មានម្ហូបអាហារហូបគ្រប់គ្រាន់ ។ ម្យ៉ាងទៀត អង្គការក៏បាននិយាយប្រាប់នៅក្នុងអង្គប្រជុំដែរថា «ឪពុកម្តាយយើងនៅតាមស្រុកស្រែចម្ការហូបចុកអាហារដូចយើងដែរ យើងមានជីវភាពស្មើៗគ្នា គ្មានវណ្ណៈនាយទុននិងសក្តិភូមិទេ មានតែវណ្ណៈកម្មករនិងកសិករប៉ុណ្ណោះ» ។

នៅទីនេះ ភ៉ាន់ តែងតែអនុគ្រោះចំពោះកម្មករណាដែលឈឺធ្វើការមិនកើត ដូចជាស្ត្រីមានជំងឺធ្លាក់សមិនអាចចុះត្រាំក្នុងទឹកបាននិងមានជំងឺប្រចាំកាយមិនអាចធ្វើការធ្ងន់ គាត់បែងចែកការងារណាស្រាលៗឲ្យធ្វើជំនួសវិញ ដូចជា ដាំស្លក្នុងរោងបាយ បេះបន្លែ ដាំបន្លែ ចិញ្ចឹមមាន់ ឬចិញ្ចឹមជ្រូកសម្រាប់ទុកហូបក្នុងអង្គភាព ។ ពេលមានអង្គប្រជុំប្រចាំខែដែលមានសមាសភាពមកពីគ្រប់អង្គភាពស្រែអំបិលដើម្បីរាយការណ៍ជូនអង្គការថ្នាក់លើពីផលិតផលដែលធ្វើបានសម្រេចនិងប្រជុំស្វ័យទិតៀន ភ៉ាន់ មិនដែលរាយការណ៍អាក្រក់ពីកម្មករទេ លើសពីនេះទៅទៀត គាត់ថែម

*ទាំងជួយនិយាយរិះរកហេតុផលដើម្បីកុំឲ្យអង្គការយកទោសកំហុសទៀត ។ ជាក់ស្តែងពេលមិត្តនារីរាយការណ៍ថាបានឃើញខាងយុវជនមកនិយាយលេងជាមួយនារីៗ រួចចោទថាខុសសីលធម៌ និងខុសវិន័យរបស់អង្គការ វ៉ាន់ ក៏ជួយនិយាយឲ្យនារីនោះរួចខ្លួនទាំងអស់ ។ វ៉ាន់ រៀបរាប់ថា «ខ្ញុំជួយមនុស្សនៅអង្គភាពជាមួយគ្នាបានច្រើននាក់ណាស់ ដូចជាឈ្មោះ នី (ស្លាប់ឆ្នាំ២០០៦), លី សព្វថ្ងៃរស់នៅភូមិភ្នំព្រឹក និង ម៉ាច សព្វថ្ងៃរស់នៅប្រទេសអូស្ត្រាលីជាដើម» ។*

*នៅឆ្នាំ១៩៧៨ វ៉ាន់ បានជួយផ្តល់ម្ហូបអាហារដល់បុរស ៨នាក់ ដែលមានសហករណ៍នៅមិនឆ្ងាយប៉ុន្មានពីអង្គភាពស្រែអំបិល ។ ពេលនោះ វ៉ាន់ បររទេះជាមួយមេក្រុមម្នាក់ដែលទុកចិត្តគ្នាមកកាប់ស្មឹកត្នោតនៅអង្គភាពស្រែអំបិល រួចដើរទៅដល់កន្លែងបុរសទាំង៨នាក់នោះដែលកំពុងតែហូបបាយមួយកញ្ចប់តូច ។ ឃើញដូច្នេះ វ៉ាន់ ក៏ប្រាប់អ្នកទាំងនោះឲ្យទៅកន្លែងរោងបាយរបស់គាត់ដើម្បីហូបបាយ ព្រោះមានម្ហូបអាហារមិនខ្វះ ។ ក្រោយពីបុរសទាំងនោះយល់ព្រមទៅជាមួយ វ៉ាន់ ក៏បញ្ជាឲ្យចុងភៅរៀបចំបាយឲ្យហូប ហើយខ្ចប់ប្រហុក និងដួកយកទៅជាមួយទៀត ។ បុរសទាំងនោះបានអរគុណ វ៉ាន់ ហើយឆ្លើយប្រាប់ថា «មិនហ៊ានយកទៅទេ» តែ វ៉ាន់ បានប្រាប់វិញថា «បើមានអ្នកណាដឹងប្រាប់ថាកន្លែងគាត់ជាអ្នកឲ្យ» ។ វ៉ាន់ បានដាំចុងភៅឲ្យរៀបបាយសម្រាប់អ្នកទាំង៨នាក់នេះរាល់ពេលដែលមកកាប់ស្មឹកត្នោត ទោះជាគាត់មិននៅក៏ដោយ ។ វ៉ាន់ រៀបរាប់ថា គាត់ព្យាយាមជួយអ្នកដទៃ គឺធ្វើតាមបណ្តាំឪពុកម្តាយដែលបានប្រាប់ថា «យើងធ្វើអំពើល្អ យើងនឹងបានល្អ» ។ ដូច្នេះ វ៉ាន់ មិនដែលគិតថាខ្លួនគាត់ត្រូវអ្នកដទៃស្អប់ទេ ។ ប៉ុន្តែ អ្វីដែល វ៉ាន់ បានគិតគឺខុសទាំងស្រុង ព្រោះនៅតែមានអ្នករាយការណ៍មិនល្អពីគាត់ដែរ ។ ដោយសារតែអំពើល្អរបស់គាត់ ទោះជាមានហេតុការណ៍ណាមួយកើតឡើងចំពោះគាត់ក៏ដោយ ក៏មានមិត្តនារីនៅក្នុងអង្គភាពជាមួយគ្នាតែងតែជួយនិយាយការពារគាត់ឲ្យរួចពីការចោទប្រកាន់ដែរ ។*

*ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ប្រជាជនមួយចំនួន និងកម្មាភិបាលខ្មែរក្រហមស្ទើរតែទាំងអស់នាំគ្នារត់ទៅព្រំដែនថៃ ព្រោះខ្លាចកងទ័ពវៀតណាមចូលមកធ្វើបាប និងដោយសារតែបានឮពាក្យគេនិយាយតៗគ្នាថា ប្រសិនបើកងទ័ពវៀតណាមចាប់បាននឹងវះពោះច្រកស្មៅ ។ ហេតុនេះហើយ វ៉ាន់ មិនបានត្រឡប់មកស្រុកកំណើតវិញទេ ។ តាមផ្លូវធ្វើដំណើរ វ៉ាន់ បានឃើញមនុស្សស្លាប់ជាច្រើន ដោយសារតែគ្មានអាហារហូបនិងឈឺគ្រុនចាញ់ ។ ព្រោះតែអាណិតអ្នកទាំងនេះ វ៉ាន់ បានចែករំលែកអង្ករដែលគាត់បានដាក់ជាប់ខ្លួនឲ្យបន្តិចបន្តួចគ្រាន់នឹងហូប ។ មួយរយៈក្រោយមក វ៉ាន់ ក៏ដូចប្រជាជនទាំងនោះដែរ គឺចាប់ផ្តើមឈឺ ហើម ។ តែសំណាងល្អ ទាហានថៃបានមកដឹកគាត់យកទៅក្នុងព្រៃប្រទេសថៃដើម្បីព្យាបាល ។ នៅទីនោះ អង្គការពិភពលោកបានជួយសង្គ្រោះ វ៉ាន់ ឲ្យមានជីវិត ថែមទាំងផ្តល់សិទ្ធិឲ្យគាត់ទៅបរទេសទៀត ។ ប៉ុន្តែកាលនោះ វ៉ាន់ គ្មានបំណងទៅក្រៅប្រទេសទេ ដូច្នេះគាត់ក៏សម្រេចចិត្តត្រឡប់ចូលដីខ្មែរវិញ ។ ក្នុងពេលធ្វើដំណើរ វ៉ាន់ បានជួយក្មេងប្រុសកំព្រាម្នាក់ឈ្មោះ ម៉ារិន អាយុប្រហែលជា ៧ឆ្នាំដែលបងប្រុសស្លាប់ដោយសារជំងឺគ្រុនចាញ់នៅស្រុកខ្មែម ។ ឃើញដូច្នេះ វ៉ាន់ មានចិត្តអាណិតព្រោះ ម៉ារិន គ្មានទីពឹងត្រូវរស់នៅម្នាក់ឯង រួចក៏យកមកចិញ្ចឹម ។ រហូតដល់ឆ្នាំ២០០៦ ឪពុកម្តាយរបស់ ម៉ារិន ក៏បានមកយក ម៉ារិន ត្រឡប់ទៅវិញ ។ វ៉ាន់ យល់ព្រមប្រគល់ក្មេងនេះទៅឲ្យឪពុកម្តាយបង្កើតរបស់ ម៉ារិន វិញដែរ ។ សព្វថ្ងៃ ម៉ារិន រស់នៅគីឡូម៉ែត្រលេខ៦ ទល់មុខរោងចក្រផលិតស្រា SKD ប្រកបមុខរបររត់ម៉ូតូកង់បី ។ ក្រៅពី ម៉ារិន វ៉ាន់ ក៏នៅចិញ្ចឹមក្មេងស្រីម្នាក់ទៀតឈ្មោះ អូន ដែលមានស្រុកកំណើតជាមួយគាត់ដែរ ។ សព្វថ្ងៃនេះ អូន បានរៀបការរួចហើយនិងផ្លាស់ទៅរស់នៅស្រុកខ្មែម ។ វ៉ាន់ រៀបរាប់ថា «អ្នកដែលគាត់ធ្លាប់ជួយនិងក្មេងដែលគាត់ធ្លាប់ចិញ្ចឹមនៅមានទំនាក់ទំនងជាមួយគ្នានៅឡើយទេ ជាពិសេស អូន រាប់អាន ម៉ារិន ដូចបងប្អូនបង្កើត ហើយបានឲ្យលុយ ម៉ារិន ធ្វើដើមរកស៊ីទៀតផង» ។ វ៉ាន់ បន្ថែមទៀតថា «ពេលជួយអ្នកដទៃគាត់មិនបានគិតថាអ្នកនោះជាអ្នកមូលដ្ឋានឬអ្នក១៧មេសាទេ ហើយក៏មិនចង់ទារសគុណមកវិញដែរ» ។*

*សព្វថ្ងៃសៅ វ៉ាន់ រស់នៅភូមិភ្នំព្រឹក ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានប្តីឈ្មោះ សាវាយ ឈាន អាយុ៥៧ឆ្នាំ និងកូនប្រុស៤នាក់ ។ ដោយសារតែអំពើល្អរបស់គាត់ ទើបធ្វើឲ្យជីវភាពរស់នៅរបស់គាត់ធូរធារដូចគេដូចឯង ។* **សុខ ខណ្ឌៈ**

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្តាប់ ដែលបានតាមដានស្តាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណ ចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្តល់ស៊ីឌីយោធតសម្លេង ។

ប្រសិនបើប្រិយមិត្តអ្នកស្តាប់ចង់ចូលរួមផ្តល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗ នៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើរមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨ ។ សូមអរគុណ ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និង ម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។